**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**
លេខ :ធ ៥០០-១៧០ ប្រក

# ប្រកាស
## ស្តីពី
## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

---

## ទេសាភិបាល ធនាគារជាតិ នៃ កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិ នៃ កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-១១៩៩-១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៣៩៨-៨៥ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាល ធនាគារជាតិ នៃ កម្ពុជា
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## ស ំ រ េ ច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.–**

ដាក់ចេញនូវបទបញ្ជាសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ដែលកំណត់អំពីល័ក្ខខ័ណ្ឌទាំងឡាយ សំរាប់អនុវត្តចំពោះការងារទូទាត់ប្រចាំថ្ងៃ នូវមូលប្បទានប័ត្រ ក្នុងចំណោមសមាជិកសភាផាត់ទាត់លើគណនីប្រាក់បញ្ញើរបស់ខ្លួន ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម។

## ប្រការ ២._ អំពីសមាជិកភាព

១- ធនាគារដែលមានបំណងចូលជាសមាជិកសភាផាត់ទាត់ ត្រូវដាក់ពាក្យស្នើសុំតាមគំរូក្នុងឧបសម្ព័ន្ធ ១ ។ ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធនាគារសាមីនឹងត្រូវបានធនាគារជាតិនៃកម្ពុជា បញ្ចូលជាសមាជិកនៅថ្ងៃធ្វើការទីមួយនៃខែបន្ទាប់ ។ សមាជិកនៃសភាផាត់ទាត់ ត្រូវបានរាយឈ្មោះក្នុងបញ្ជីរាយនាមដូចមានក្នុងឧបសម្ព័ន្ធ ២ ។

២- ធនាគារដែលមិនមែនជាសមាជិក ត្រូវបានអនុញ្ញាតអោយមានតំណាងក្នុងសភាផាត់ទាត់ជំនួសខ្លួន ដោយធនាគារជាសមាជិក ចំពោះសំណូមពរផាត់ទាត់ និងទូទាត់មូលប្បទានប័ត្រ ។ ការសុំអោយមានតំណាងនេះ ត្រូវបានយល់ព្រមជាលាយល័ក្ខណ៍អក្សរដោយធនាគារជាតិនៃកម្ពុជា ជាមុន ។

## ប្រការ ៣._ លក្ខណៈសម្បត្តិជាសមាជិក

១- ធនាគារដែលធនាគារជាតិនៃកម្ពុជាចេញអាជ្ញាប័ណ្ណអោយប្រកបអាជីវកម្មអាចសុំចូលជាសមាជិក ។ បែបបទនៃការស្នើសុំរួមមាន ÷

- ពាក្យសុំចូលជាសមាជិកដែលមានចុះហត្ថលេខានាយកធនាគារ ឬ អ្នកដែលទទួលសិទ្ធិប្រទាន
- ច្បាប់ថតចំលងនៃអាជ្ញាប័ណ្ណដែលចេញដោយធនាគារជាតិនៃកម្ពុជា
- លិខិតឧទ្ទេសនាម និង គំរូហត្ថលេខា ។

លើសពីនេះទៀត ធនាគារជាសមាជិកត្រូវ ÷

- មានគណនីចរន្តជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា
- បង់សោហ៊ុយសេវា តាមការកំណត់របស់ ធនាគារជាតិនៃកម្ពុជា ។

២- ធនាគារជាសមាជិក ត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញ ។

## ប្រការ ៤._ ការបាត់បង់សមាជិកភាព

១- ធនាគារ ដែលត្រូវបានធនាគារជាតិនៃកម្ពុជាដកហូតអាជ្ញាប័ណ្ណ ពុំអាចចូលរួមក្នុងសភាផាត់ទាត់បានទេ ។

២- ធនាគារ អាចដកខ្លួនចេញដោយស្ម័គ្រចិត្តពីសភាផាត់ទាត់ អោយតែធនាគារនោះបានធ្វើការសំរបសំរួលត្រឹមត្រូវជាមួយនឹងធនាគារមួយទៀតជាសមាជិក អោយកាន់កាប់មូលប្បទានប័ត្រដើម្បីផាត់ទាត់ជំនួសខ្លួន ដោយមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា ជាមុន ។

## ប្រការ ៥._ ធនាគារទូទាត់

ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំថ្ងៃ អំពីទឹកប្រាក់សរុបនៃមូលប្បទានប័ត្រ ដែលសភាផាត់ទាត់បានបញ្ជូនទៅ និងទទួលយក និងគណនាទឹកប្រាក់សុទ្ធដែលត្រូវចុះឥណពន្ធ ឬ ចុះឥណទាន គណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ ។

**ប្រការ ៦._ អំពីការគ្រប់គ្រង**

ធនាគារជាតិនៃកម្ពុជា ត្រូវជ្រើសតាំងប្រធានសភាផាត់ទាត់ ដែលទទួលបន្ទុកប្រតិបត្តិការសភាផាត់ទាត់ ។ ប្រធានអាចប្រគល់ភារកិច្ចត្រួតពិនិត្យ និង តាមដានមុខងារប្រចាំថ្ងៃទៅអោយអ្នកដឹកនាំផាត់ទាត់ ។ ប្រធានសភាផាត់ទាត់ និង អ្នកដឹកនាំផាត់ទាត់ត្រូវតែជាមន្ត្រីធនាគារជាតិនៃកម្ពុជា ។

២- ករណីកើតមានវិវាទ រវាងតំណាងរបស់ធនាគារសមាជិក ក្នុងពេលប្រគល់ ឬទទួលការទូទាត់ ឬពាក់ព័ន្ធជាមួយទឹកប្រាក់ត្រូវទូទាត់ ការសំរេចរបស់អ្នកដឹកនាំផាត់ទាត់ អាចត្រូវទទួលយកជាបណ្តោះអាសន្ន ដោយមានទិដ្ឋាការរបស់ប្រធានសភាផាត់ទាត់ ។ ក្នុងករណីនៅបន្តមានការជំទាស់ក្រោយការសំរេច ការដោះស្រាយត្រូវធ្វើដោយផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ ។

**ប្រការ ៧._ គណៈកម្មាធិការប្រតិបត្តិការ**

១- ការងារសភាផាត់ទាត់អាចត្រូវបន្ថែមដោយគណៈកម្មាធិការប្រតិបត្តិការដែលរួមមានតំណាងមួយរូបរបស់ធនាគារសមាជិកនីមួយៗ និងដឹកនាំដោយប្រធានមួយរូបជ្រើសរើសដោយសមាជិក ។ ប្រធានត្រូវបំរើការរយៈពេលមួយឆ្នាំ ។ អ្នកដឹកនាំបន្ទាប់នឹងត្រូវតែងតាំង និងបោះឆ្នោតជ្រើសរើសដោយសមាជិកសភាផាត់ទាត់ ។

២- គណៈកម្មាធិការប្រតិបត្តិការ មានមុខងារដូចតទៅ ÷

- ពិគ្រោះផ្តល់យោបល់ដើម្បីលើកកំពស់គុណភាពប្រតិបត្តិការផាត់ទាត់
- ពង្រឹងសណ្តាប់ធ្នាប់ និងវិន័យរបស់តំណាងសមាជិក
- អនុវត្តអោយបានប្រសើរឡើងនូវភារកិច្ចដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬ ដោយគណៈកម្មាធិការ ។

៣- គណៈកម្មាធិការប្រតិបត្តិការត្រូវជួបប្រជុំយ៉ាងហោចណាស់៤ដងក្នុងមួយឆ្នាំ ។ ការប្រជុំបន្ថែមអាចធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ឬនៅពេលមានសំណូមពរជាលាយល័ក្ខណ៍អក្សររបស់សមាជិកពីររូបយ៉ាងតិច ដោយមានបញ្ជាក់ច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា ។

**ប្រការ ៨._ ការកែប្រែបទបញ្ជា**

ខ្លឹមសារនិងល័ក្ខខ័ណ្ឌនៃបទបញ្ជាផាត់ទាត់អាចនឹងត្រូវកែប្រែពីពេលមួយទៅពេលមួយ តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានការព្រមព្រៀងជាមួយគណៈកម្មាធិការប្រតិបត្តិការ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាអាចពង្រីកប្រតិបត្តិការផាត់ទាត់ទៅខេត្ត-ក្រុងដទៃទូទាំងប្រទេស បន្ថែមសេវាផ្សេងៗទៀតបើយល់ថាចាំបាច់ ដើម្បីធ្វើអោយប្រសើរឡើងនូវប្រព័ន្ធទូទាត់ ។

# ជំពូកទី ២
## និយមន័យនៃ ពាក្យបច្ចេកទេស

**ប្រការ ៩._**

ពាក្យបច្ចេកទេសដែលបានប្រើក្នុងបទបញ្ជាមាននិយមន័យដូចតទៅនេះ ÷

១- ថ្ងៃធ្វើការ (Business day) គឺពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ឬ ថ្ងៃបន្ថែមណាមួយដែលធនាគារជាតិនៃកម្ពុជាបានកំណត់បើកធ្វើការ ។ ថ្ងៃធ្វើការមិនរាប់បញ្ចូលថ្ងៃឈប់សំរាកជាសាធារណៈទេ ។

២- សភាផាត់ទាត់ (Clearing House) គឺជាមណ្ឌលសំរួលការផាត់ទាត់ ដែលធ្វើឡើងដោយធនាគារជាតិនៃកម្ពុជា នៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅភ្នំពេញ ។

៣- ឧបករណ៏ទូទាត់ (Payment or item) គឺជាមូលប្បទានប័ត្រចេញផ្សាយលើគណនីចរន្តរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ មូលប្បទានប័ត្រគឺជាបញ្ជារបស់ម្ចាស់គណនីនៅធនាគារមួយ អោយទូទាត់ប្រាក់ពីគណនីនោះទៅអោយអត្ថគាហក ។

៤- ឧបករណ៏បង្វិលវិញ ឬ មិនទូទាត់ (Returned or unpaid item) គឺជាមូលប្បទានប័ត្រដែលមិនអាចទូទាត់ដោយសមាជិកទទួល ដោយមូលហេតុទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ ៣ ។

៥- ឧបករណ៏ដែលអាចទទួលយកបាន ( Eligible items ) នៅសភាផាត់ទាត់រួមមាន ÷

- ក- មូលប្បទានប័ត្ររបស់ធនាគារ ដែលបានចេញផ្សាយដោយតតិយជន ត្រូវសងទៅអោយតតិយជននៅទីស្នាក់ការធនាគារប្រតិស្រុតនៅភ្នំពេញ ។
- ខ- មូលប្បទានប័ត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- គ- ឧបករណ៏ឥណពន្ធខ្លះទៀតដែលធនាគារជាតិនៃកម្ពុជា កំណត់ថាអាចទទួលយកបាន។ មូលប្បទានប័ត្រត្រូវបានចេញផ្សាយតាមទ្រង់ទ្រាយអនុញ្ញាត ដែលបានផ្តល់ដោយធនាគារមានលំនាំស្តង់ដារដូចដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា ។ មូលប្បទានប័ត្រអាចត្រូវចេញផ្សាយជាភាសាខ្មែរ អង់គ្លេស ឬ បារាំង ។

៦- សមាជិក (Participant) គឺជាធនាគារ ដែលបានយល់ព្រមចូលរួមក្នុងសភាផាត់ទាត់ក្រោមខ្លឹមសារ និងល័ក្ខខ័ណ្ឌនៃបទបញ្ជានេះ ។

៧- ការចូលរួម (Participation) គឺជាវត្តមានក្នុងគ្រាផាត់ទាត់ប្រចាំថ្ងៃរបស់សភាផាត់ទាត់។ សមាជិកត្រូវចូលរួមរាល់គ្រាផាត់ទាត់ ទោះបីមាន ឬគ្មានមូលប្បទានប័ត្រដើម្បីបញ្ជូនទៅសមាជិកដទៃក្តី ។

៨- សមាជិកទទួល (Receiving Participant) គឺជាសមាជិកដែលទទួលការទូទាត់ជាមូលប្បទានប័ត្រតាមរយៈសភាផាត់ទាត់។ សមាជិកនេះក៏អាចហៅផងដែរថាជាធនាគារចំណាយសង(Paying Bank)។

៩- សមាជិកប្រគល់ (Sending participant) គឺជាសមាជិកដែលប្រគល់មូលប្បទានប័ត្រសំរាប់ការទូទាត់តាមរយៈសភាផាត់ទាត់ ។

១០- កិច្ចបញ្ជិការ (Books) គឺជាការកត់ត្រាគណនេយ្យលើគណនីអតិថិជន ដែលបើកនៅធនាគារ និង គណនីចរន្តរបស់ធនាគារ ដែលបើកនៅធនាគារជាតិនៃកម្ពុជា ។

១១- ការកត់ត្រា(Posting) គឺជាការចុះឥណពន្ធគណនីអតិថិជនសំរាប់មូលប្បទានប័ត្រដោយធនាគារទទួល ។

១២- ការទូទាត់ (Settlement) គឺជាលេខនានៃឥណពន្ធសុទ្ធ ឬឥណទានសុទ្ធក្នុងគណនីផាត់ទាត់របស់ធនាគារជាសមាជិក សំរាប់ការផាត់ទាត់ប្រចាំថ្ងៃ ។ ការទូទាត់ទាំងអស់ត្រូវបានធ្វើជាបណ្តោះអាសន្ន និងអាចត្រូវដកហូតមកវិញចំពោះការទូទាត់ណាដែលត្រូវបដិសេធដោយសមាជិកទទួល ហើយបង្វិលវិញដូចដែលបានចែងក្នុងបទបញ្ជា ។

១៣- លេខអត្តសញ្ញាណ (Routing number) គឺជាលេខសំគាល់របស់សមាជិក ដូចដែលបានរាយក្នុងសៀវភៅរាយឈ្មោះរបស់ធនាគារដែលកាន់កាប់ដោយធនាគារជាតិនៃកម្ពុជា ។ លេខអត្តសញ្ញាណត្រូវបានប្រើដើម្បីជ្រើសរើសនូវការទូទាត់ក្នុងចំណោមសមាជិកនៃសភាផាត់ទាត់ និងត្រូវបោះពុម្ពត្រង់កន្លែងសមស្របលើមូលប្បទានប័ត្រ ដោយអនុលោមតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា ។

១៤- គ្រាផាត់ទាត់ (Session) គឺជាការប្រជុំរបស់សមាជិកសភាផាត់ទាត់ដើម្បីប្តូរមូលប្បទានប័ត្រទៅវិញទៅមក ។ គ្រាផាត់ទាត់សំខាន់នឹងប្រព្រឹត្តទៅនៅម៉ោង ១០:០០ ព្រឹក ហើយគ្រាផាត់ទាត់បន្ទាប់បន្សំសំរាប់បង្វិលវិញនូវមូលប្បទានប័ត្រប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល ។ ប៉ុន្តែ ប្រធានអាចសំរេចយក គ្រាផាត់ទាត់បន្ថែមក្នុងថ្ងៃណាមួយ ប្រសិនបើយល់ថាចាំបាច់ ។

១៥- គណនីផាត់ទាត់ (Clearing Account ) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជា សំរាប់ទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាផាត់ទាត់ ។ គណនីនេះត្រូវបានប្រើសំរាប់ទូទាត់កាតព្វកិច្ចរបស់សភាផាត់ទាត់ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវរបស់ធនាគារប្រគល់

**ប្រការ ១០._**

ធនាគារទាំងឡាយត្រូវប្រើប្រាស់សភាផាត់ទាត់ ដើម្បីប្រគល់មូលប្បទានប័ត្រទៅអោយសមាជិកដទៃ ។ ការប្រគល់មូលប្បទានប័ត្រទ្វេភាគី ក្រៅពីគ្រាប្រជុំនៃសភាផាត់ទាត់ ត្រូវបានអនុញ្ញាតតែលើការព្រមព្រៀងទៅវិញទៅមក ពិសេសរវាងសមាជិកសភាផាត់ទាត់ផ្ទាល់ ។

**ប្រការ ១១._**

សមាជិកប្រគល់ត្រូវ ÷

១- **អនុញ្ញាតនិងកំណត់អត្តសញ្ញាណនៃការប្រគល់**

មូលប្បទានប័ត្រទាំងអស់ត្រូវបោះត្រារបស់សមាជិកប្រគល់ និងកាលបរិច្ឆេទនៃការបញ្ជូន នៅខាងខ្នងនៃមូលប្បទានប័ត្រនីមួយៗ ។

**២- រៀបចំការប្រគល់អោយបានត្រឹមត្រូវ**

សមាជិកប្រគល់ម្នាក់ៗ ត្រូវរៀបចំតារាងនៃមូលប្បទានប័ត្រជាពីរច្បាប់គំរូ PPC001 បង្ហាញនូវទឹកប្រាក់នៃមូលប្បទានប័ត្រនីមួយៗ និងតំលៃសរុបនៃមូលប្បទានប័ត្រដែលត្រូវដកប្រាក់(Draw on) ពីសមាជិកដទៃ ។ ឧទាហរណ៍នៃគំរូទាំងអស់បង្ហាញក្នុងឧបសម្ព័ន្ធ៤ ។ តារាងគំរូ PPC001 ត្រូវបានរៀបចំសំរាប់សមាជិកនីមួយៗ ដោយបង្ហាញនូវ ÷

ក- ទឹកប្រាក់សរុប និង ចំនួននៃមូលប្បទានប័ត្រចេញផ្សាយនៅបណ្តុំទីស្នាក់ការភ្នំពេញ ដែលបានបង្ហាញដល់សមាជិកទាំងនោះ និង

ខ- មូលប្បទានប័ត្រមិនទូទាត់ បង្វិលវិញ និងមិនអាចទទួលយកបាន ។

សមាជិកប្រគល់ម្នាក់ៗ ត្រូវប្រគល់ថាសកុំព្យូទ័រមួយដែលមានផ្ទុកនូវតារាងនៃគំរូ PPC001 ។

**៣- ចូលរួមទៀងទាត់ក្នុងគ្រាផាត់ទាត់**

មូលប្បទានប័ត្រត្រូវបានយកទៅសភាផាត់ទាត់នៅម៉ោងកំណត់ ឬមុនម៉ោងកំណត់នៃថ្ងៃធ្វើការនីមួយៗ សមាជិកដែលតំណាងរបស់ខ្លួនមកដល់យឺតក្រោយពេលកំណត់គ្រាផាត់ទាត់លើសពី៥នាទី អាចត្រូវផ្អាកមិនអោយចូលរួមគ្រាផាត់ទាត់នោះ ដោយអ្នកដឹកនាំផាត់ទាត់ ។ សមាជិកដែលត្រូវផ្អាកមិនអោយចូលរួមក្នុងគ្រាផាត់ទាត់ មិនអាចប្រគល់មូលប្បទានប័ត្រទៅសមាជិកដទៃឡើយ ។ ប៉ុន្តែ សមាជិកនោះត្រូវទទួលយក ហើយគណនីរបស់ខ្លួនត្រូវបានចុះឥណពន្ធនូវមូលប្បទានប័ត្រដែលសមាជិកដទៃប្រគល់អោយខ្លួន ។

**៤- អនុញ្ញាតអោយចុះឥណពន្ធគណនីចំពោះមូលប្បទានប័ត្របង្វិលវិញ**

ក្នុងករណីមានការបង្វិលវិញនៃមូលប្បទានប័ត្រដែលបានបដិសេធដោយសមាជិកទទួល សមាជិកប្រគល់ត្រូវអនុញ្ញាតអោយធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធគណនីចរន្តរបស់ខ្លួនវិញ ។

**៥- រក្សាទុកនូវការកត់ត្រា**

សមាជិកប្រគល់ត្រូវរក្សាទុកនូវការកត់ត្រាពាក់ព័ន្ធទាំងអស់ដែលចាំបាច់ ដើម្បីបង្កើតឡើងវិញនូវការផ្ញើ ឬការទូទាត់ដាច់ពីគ្នា សំរាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទបង្ហាញដំបូង ។ ប៉ុន្តែ នេះមិនបញ្ជាក់នូវកាតព្វកិច្ចដើម្បីស្រាវជ្រាវ ផ្តល់នូវការទាក់ទងអតិថិជន ឬដោះស្រាយនូវការកែតំរូវការទូទាត់យឺតជាងរយៈពេលនេះទេ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវរបស់ធនាគារទទួល

**ប្រការ ១២._**

ធនាគារទទួល ត្រូវទទួលយកមូលប្បទានប័ត្រ ដែលបានប្រគល់អោយខ្លួននៅសភាផាត់ទាត់រៀងរាល់ថ្ងៃ ដោយរួមបញ្ចូលទាំងមូលប្បទានប័ត្រមិនទូទាត់ដូចមានចែងក្នុងប្រការ ១១ ។ មូលប្បទានប័ត្រ ដែលត្រូវ

ប្រគល់អោយសមាជិកទទួល ក៏ប៉ុន្តែមិនបានទទួលយកដោយសារតែការមិនបានចូលរួមក្នុងគ្រា ផាត់ទាត់ ឬត្រូវបានផ្អាកមិនអោយចូលរួម ដោយសារការមកដល់យឺតក្នុងថ្ងៃនោះ ត្រូវចាត់ទុកថា បានប្រគល់នៅថ្ងៃនោះ ដើម្បីសំណូមពរទូទាត់និងបង្វិលវិញទាន់ពេលនូវមូលប្បទានប័ត្រមិនទូទាត់ ។

**ប្រការ ១៣_** សមាជិកទទួលត្រូវ ÷

១- **បញ្ជាក់នូវការយល់ព្រមទទួល** (Certify Acceptance)

សមាជិកទទួល ត្រូវចុះហត្ថលេខាលើច្បាប់ចំលងនៃតារាង PPC001 ដើម្បីទទួលស្គាល់ការទទួលមូលប្បទានប័ត្រនៅសភាផាត់ទាត់ ។ សមាជិកទទួលនីមួយៗ ត្រូវចុះហត្ថលេខាលើច្បាប់ចំលងនៃតារាង PPC002 ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីទទួលស្គាល់នូវចំនួនទឹកប្រាក់ត្រូវចុះឥណពន្ធ ឬ ឥណទានក្នុងគណនីផាត់ទាត់របស់ខ្លួនជាលទ្ធផលនៃគ្រាផាត់ទាត់ ។

២- **ទូទាត់សង ឬបង្វិលវិញនូវមូលប្បទានប័ត្រ** (Settle for or return payment)

មូលប្បទានប័ត្រនៅតែជាកម្មសិទ្ធិរបស់សមាជិកប្រគល់រហូតដល់ត្រូវបានទូទាត់សងឬត្រូវបានបង្វិលវិញ។ សមាជិកទទួលកាន់កាប់មូលប្បទានប័ត្រជាការផ្ញើទុក(In trust)រហូតដល់គេបានទទួលឥណទានពីបហារីក(Drawer)នៃមូលប្បទានប័ត្រ ដោយចុះចូលគណនីរបស់អតិថិជនខ្លួន ។ សមាជិកទទួលត្រូវមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីផាត់ទាត់របស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចប្រចាំថ្ងៃ ។

៣- **បង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់** (Return unpaid or dishonored payments)

ក- បទប្បញ្ញត្តិទូទៅ ( General Provision)

មូលប្បទានប័ត្រមិនទូទាត់ឬបដិសេធ ត្រូវបានបង្វិលមកវិញតាមរយៈសភាផាត់ទាត់ ។ សមាជិកទទួល ត្រូវបញ្ជាក់អោយច្បាស់លើមូលប្បទានប័ត្របង្វិលវិញនូវមូលហេតុដែលបានព្រមព្រៀងដូចមានរាយក្នុងឧបសម្ព័ន្ធ ៣ និងឈ្មោះរបស់សមាជិកទទួល ។

ខ- បង្វិលវិញអោយទាន់ពេល (Timely return)

មូលប្បទានប័ត្រដែលត្រូវបង្វិលវិញតាមរយៈសភាផាត់ទាត់ ត្រូវធ្វើការបង្វិលវិញអោយទាន់ពេល ហើយសមាជិកទទួលមិនត្រូវបានបង្ខំអោយទទួលខុសត្រូវចំពោះមូលប្បទានប័ត្រនោះទេ ប្រសិនបើមូលប្បទានប័ត្រនោះត្រូវបានបង្វិលវិញ មិនយឺតជាងម៉ោង ៣ :០០រសៀល នៃថ្ងៃផាត់ទាត់ ។ មូលប្បទានប័ត្រមិនត្រូវបានចាត់ទុកថា ទូទាត់បញ្ចប់ជាមួយនឹងការសងជំរះ ជាសាច់ប្រាក់ទេ រហូតដល់ក្រោយពេលបិទគ្រាបង្វិលវិញ ។

គ- ការទូទាត់សំរាប់ការបង្វិលវិញ (Settlement for return)

សមាជិកទទួល ត្រូវបង្វិលវិញនូវមូលប្បទានប័ត្រមិនទូទាត់ដែលបានបញ្ជាក់ច្បាស់ថាមូលប្បទានប័ត្របង្វិលវិញ (Return item) តាមគំរូស្តង់ដារកំណត់ ។ ចំនួនទឹកប្រាក់ត្រូវបានដកចេញវិញពីក្នុងទឹកប្រាក់ទូទាត់សុទ្ធសំរាប់សមាជិកទទួល ( គំរូ PPC001) ។

ឃ- ការផុតកំណត់នៃសិទ្ធិបង្វិលវិញ (Expiration of return privilege)

មូលប្បទានប័ត្រអាចមិនទូទាត់និងបង្វិលវិញបានតែពីរលើកប៉ុណ្ណោះ ។ មូលប្បទានប័ត្រដែលនៅតែមិនទូទាត់បន្ទាប់ពីការបដិសេធ ( Dishonor) លើកទីពីរ ត្រូវតែដកចេញពីបណ្តូញនៃសភាផាត់ទាត់ ដោយទុកអោយធ្វើបេឡានិច័យផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ ។

៤- **ការរក្សាទុកនូវការកត់ត្រា**

សមាជិកទទួល ត្រូវរក្សាទុកនូវថាសកុំព្យូទ័រ ឬក្រដាសតារាង និងវត្ថុសំអាងជាក់ស្តែងផ្សេងៗទៀត ដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការកត់ត្រាសំរាប់ប្រតិបត្តិការរបស់សភាផាត់ទាត់ សំរាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទទទួល ។ សមាជិកទទួល មិនស្ថិតក្រោមកាតព្វកិច្ចទេ ប៉ុន្តែអាចជួយសមាជិកប្រគល់ក្នុងការដោះស្រាយតំរូវការស្តីពីប្រតិបត្តិការ ដែលកើតមានឡើងបន្ទាប់ពីរយៈពេលរក្សាទុកនៃការកត់ត្រាចាំបាច់បានផុតកំណត់ ។

៥- **ការបង្វិលវិញនៃមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងករណីមានកំហុស**

ក្នុងករណីសមាជិកមិនមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា សំរាប់ការទូទាត់ប្រចាំថ្ងៃ និងត្រូវបាននាយកដ្ឋានត្រួតពិនិត្យធនាគារប្រកាសថា មានអសាធនភាព ធនាគារជាតិនៃកម្ពុជានឹងត្រូវជូនដំណឹងដល់សមាជិកដទៃ និងទាមទារអោយសមាជិកមិនបានទូទាត់នោះបង្វិលវិញជាបន្ទាន់ នូវមូលប្បទានប័ត្រមិនបានកត់ត្រាក្នុងកម្មសិទ្ធិរបស់ខ្លួន ទៅអោយធនាគារជាតិនៃកម្ពុជា។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជានឹងបង្វិលមូលប្បទានប័ត្រនោះ ទៅអោយសមាជិកដែលប្រគល់ពីដំបូងវិញ ។

## ជំពូកទី ៥
## ការទទួលខុសត្រូវរបស់ធនាគារជាតិ នៃ កម្ពុជា

**ប្រការ ១៤._**

ធនាគារជាតិនៃកម្ពុជា គឺជាសមាជិកមួយនៃសភាផាត់ទាត់ ដែលអាចទទួលនិង ប្រគល់ មូលប្បទានប័ត្រដូចគ្នានឹងសមាជិកដទៃសំរាប់សងអោយគេឬទារយកពីគេ ។ លើសពីនេះធនាគារជាតិនៃកម្ពុជាសំរួលដល់គ្រាផាត់ទាត់ និងទូទាត់គណនីទាំងឡាយក្នុងបញ្ជីរបស់ខ្លួន ដែលបានបើកអោយសមាជិកទាំងអស់ ។

**ប្រការ ១៥._ ការរៀបចំគំរូ** ( Preparation of form)

អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំនូវគំរូ PPC002 និងPPC003 ដោយឧបករណ៍អេឡិចត្រូនិចដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ ៤ ដោយបញ្ចូលក្នុងតារាងកិច្ចការកុំព្យូទ័ររបស់សមាជិក ( គំរូ PPC001) ពីថាសដែលបានយកមកក្នុងគ្រាផាត់ទាត់ ។

**ប្រការ ១៦._ ការទូទាត់** (Settlement)

១- ការទូទាត់នឹងត្រូវបានអនុវត្តចប់សព្វគ្រប់នៅថ្ងៃធ្វើការនីមួយៗ ដោយការចុះឥណពន្ធនិងចុះឥណទាន គណនីចរន្តរបស់សមាជិកដែលបើកនៅធនាគារជាតិនៃកម្ពុជា ។ នៅពេលដែលចំនួនទឹកប្រាក់សរុប នៃមូលប្បទានប័ត្រប្រគល់ លើសចំនួនទឹកប្រាក់សរុបនៃមូលប្បទានប័ត្រទទួល គណនីរបស់សមាជិកនឹងត្រូវចុះឥណទាន ។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូល្បទានប័ត្រទទួល លើសចំនួនទឹកប្រាក់នៃមូលប្ប-ទានប័ត្រប្រគល់ គណនីរបស់សមាជិកនឹងត្រូវចុះឥណពន្ធ ។ នៅពេលដែលអ្នកដឹកនាំផាត់ទាត់ពិនិត្យឃើញថា គំរូទូទាត់របស់សភាផាត់ទាត់មានតុល្យភាពហើយនោះ អ្នកដឹកនាំផាត់ទាត់ត្រូវចុះហត្ថលេខាលើ ច្បាប់ចំលងឬតារាងបោះពុម្ពចេញនៃគំរូ PPC002 របស់សមាជិកនីមួយៗ ទុកជាប្រកាសឥណពន្ធ ឬឥណទានក្នុងគណនីចរន្តរបស់សមាជិកនោះ ។បន្ទាប់មកអ្នកដឹកនាំផាត់ទាត់ត្រូវប្រកាសថាគ្រាផាត់ទាត់ត្រូវបញ្ចប់ ។ សមាជិកណាក៏មិនអាចចាកចេញមុនពេលប្រកាសបញ្ចប់គ្រាផាត់ទាត់បានឡើយ ។

២- ក្នុងករណីដែលសមាជិកទទួល មានមូលនិធិមិនគ្រប់គ្រាន់ក្នុងគណនីចរន្តដើម្បីទូទាត់ សមាជិកនោះមានរយៈពេល២ម៉ោងដើម្បីសំរបសំរួលមូលនិធិពីធនាគារផ្សេងមួយទៀត ដើម្បីដាក់បញ្ចូលក្នុងគណនី ចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ។ នេះគឺជាប្រភពចំបង និងរំពឹងបាននៃមូលនិធិសំរាប់ការទូទាត់ ។

**ប្រការ ១៧._ សមតុល្យដែលបានតំកល់នៅធនាគារជាតិនៃកម្ពុជា** (Balance maintained at NBC)

សមាជិកទាំងអស់ត្រូវអនុញ្ញាតអោយធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធលើគណនីចរន្តរបស់ពួកគេនូវចំនួនទឹកប្រាក់ដែលជាលទ្ធផលសុទ្ធនៃការផាត់ទាត់មូលប្បទានប័ត្រ និងត្រូវតំកល់មូលនិធិក្នុងគណនីចរន្តទាំងនោះអោយមានគ្រប់គ្រាន់ ដើម្បីចុះឥណពន្ធ ។ ជាវិធានការប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជា អាចទាមទារអោយធនាគារសមាជិកតំកល់អោយបានគ្រប់គ្រាន់ នូវប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងគណនី ផ្សេងដើម្បីធានាក្នុងការចុះឥណពន្ធសុទ្ធធំបំផុតដែលកើតមានក្នុងត្រីមាសមុន ។

**ប្រការ ១៨._ ការទូទាត់មិនបាន** (Failure to settle)

១- ប្រសិនបើសមាជិកមិនផ្តល់នូវការធានាចំពោះកាតព្វកិច្ចចុះឥណពន្ធសុទ្ធរបស់ខ្លួន ក្នុងសភាផាត់ទាត់ ក្នុងរយៈពេលអនុញ្ញាត២ម៉ោងនោះទេ អ្នកដឹកនាំផាត់ទាត់នឹងជូនដំណឹងចំពោះប្រធានសភាផាត់ទាត់ដែលនឹងកំណត់នូវវិធានការកែលំអ ។ ប្រសិនបើ ធនាគារជាតិនៃកម្ពុជា បានប្រកាសថា សមាជិកនោះ"មានកំហុស (In default)" ប្រធានសភាផាត់ទាត់នឹងជូនដំណឹងចំពោះសមាជិកដទៃទៀត ។ គ្រាផាត់ទាត់មិនត្រូវបានប្រកាសបិទទេ លើកលែងតែគណនីទាំងអស់ត្រូវបានចុះឥណពន្ធជាស្ថាពរនៅថ្ងៃផាត់ទាត់នោះ ។

២- ក្នុងករណីកំហុសត្រូវបានប្រកាសក្នុងគ្រាផាត់ទាត់ ធនាគារជាតិនៃកម្ពុជាត្រូវធ្វើនិយ័តកម្ម (Unwind) នូវការទូទាត់ ពោលគឺ ចុះបញ្ច្រាសនូវឥណទានដែលបានផ្តល់អោយធនាគារទទួល ចំពោះមូលប្បទានប័ត្ររបស់ខ្លួនដែលយកទៅអោយសភាផាត់ទាត់ និង ចុះបញ្ច្រាសនូវឥណពន្ធចំពោះមូលប្បទានប័ត្រដែលបានយកដោយធនាគារដទៃ ហើយគណនាជាថ្មីនូវស្ថានភាពសុទ្ធរបស់សមាជិកទាំងអស់ស្របតាម

នោះ ។ អ្នកដឹកនាំផាត់ទាត់ត្រូវរៀបចំគំរូជាថ្មី ដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពថ្មីរបស់សមាជិកទាំងអស់ ។ ធនាគារមានកំហុសនឹងមិនត្រូវបានអនុញ្ញាតអោយចូលរួមក្នុងការផាត់ទាត់ទៀតឡើយ ។

**ប្រការ ១៩._ ព្រំដែននៃការទទួលខុសត្រូវ** (Limit of liability )

ធនាគារជាតិនៃកម្ពុជា មិនទទួលខុសត្រូវនិងមិនទទួលសងឡើយ ក្នុងករណីដែលសមាជិកមានការខាតបង់ ក្នុងទំនាក់ទំនងជាមួយសមាជិកសភាផាត់ទាត់ លើកលែងតែក្នុងករណីនៃការធ្វេសប្រហែសនិងការដឹកនាំមិនត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាផ្ទាល់ ។ ការតវ៉ាទាំងអស់អំពីការបែងចែកមិនត្រឹមត្រូវ ការបង្វិលវិញមិនទាន់ពេល ការខកខានមិនបានបង្វិលវិញនូវមូលប្បទានប័ត្រ កំហុសរបស់សមាជិក ។ល។ ត្រូវតែដោះស្រាយដោយផ្ទាល់រវាងអ្នកចូលរួមទាំងអស់ លើកលែងតែសមាជិកទាំងនោះយល់ព្រមប្រើប្រាស់បញ្ជីរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីកត់ត្រាប្រតិបត្តិការ ។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាត្រូវទទួលខុសត្រូវទៅនឹងខ្លឹមសារ និងល័ក្ខខ័ណ្ឌនៃបទបញ្ជាសំរាប់មូលប្បទានប័ត្ររបស់ខ្លួនផ្ទាល់ ដែលបានបញ្ចូលដើម្បីផាត់ទាត់ និងទូទាត់តាមរបៀបដូចគ្នានឹងសមាជិកដទៃទៀត ។

## ជំពូកទី ៦

## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ២០._ ច្បាប់សំរាប់គ្រប់គ្រង** (Governing Law)

ប្រតិបត្តិការដែលឋិតនៅក្រោមបទបញ្ជានេះ ត្រូវតែអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ជាផ្សេងៗទៀតរបស់ធនាគារជាតិនៃកម្ពុជា ដែលបានផ្សព្វផ្សាយអោយអនុវត្តនូវគ្រប់ករណី ។

**ប្រការ ២១._ ល័ក្ខខ័ណ្ឌភាពអាសន្ន** ( Emergency Conditions)

ការដឹកនាំប្រតិបត្តិការផាត់ទាត់ប្រចាំថ្ងៃអាចត្រូវពន្យារពេលពេញមួយថ្ងៃធ្វើការ ឬ អាចត្រូវលើកទៅថ្ងៃបន្ទាប់ ក្នុងករណីដែលសមាជិកមិនមានលទ្ធភាពអាចចូលរួមបាន ដោយសារតែមានភាពអាសន្ន ដូចជាអាកាសធាតុ ការដាច់ចរន្តអគ្គិសនី ទូរគមនាគមន៍ ការចលាចលធំៗក្នុងទីក្រុង ឬក្នុងប្រទេស ។ ក្នុងកាលៈទេសៈនេះ ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការណែនាំជាក់លាក់ ចំពោះសមាជិកទាំងអស់ទាក់ទងនឹងនីតិវិធីសំរាប់អនុវត្តក្នុងការផាត់ទាត់ ឬត្រូវបង្វិលវិញ ។ ទោះយ៉ាងណាក្តី សមាជិកនីមួយៗ គួរដោះស្រាយតាមលទ្ធភាពរបស់ខ្លួនចំពោះការរំខាននោះ និង ត្រូវទទួលខុសត្រូវក្នុងការរក្សាគំរោងការ និង ទីកន្លែងដំណើរការដោយមានសំភារៈបរិក្ខារចាំបាច់ដើម្បីបន្តប្រតិបត្តិការសំរាប់រយៈពេល បន្ទាន់ៗ ។

**ប្រការ ២២._ អំពីស្ថិតិ** ( Statistics)

ធនាគារជាតិនៃកម្ពុជាត្រូវចងក្រងនិងផ្សព្វផ្សាយនូវស្ថិតិប្រចាំខែស្តីពីចំនួននិងទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានផាត់ទាត់ប្រចាំថ្ងៃពេញមួយខែ ដោយបញ្ចូលពត៌មាន ស្តីពីមូលប្បទានប័ត្របង្វិលវិញ ( មូលប្បទានប័ត្រមិនទូទាត់) ។ លំដាប់លំដោយនៃស្ថិតិត្រូវប្រៀបធៀបមធ្យមប្រចាំខែសំរាប់ឆ្នាំនេះ និងឆ្នាំមុន ។

ពតិមានស្តីពីការផាត់ទាត់របស់ធនាគារសមាជិកនីមួយៗ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ លើកលែងតែចំពោះធនាគារសាមី ។

**ប្រការ ២៣._**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២៤._**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងធនាគារជាសមាជិកសភាផាត់ទាត់មូលប្បទានប័ត្រចារីកជារៀល ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ២៥._**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០២

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ២៤
  " ដើម្បីអនុវត្ត "
- ឯកសារ
- កាលប្បវត្តិ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពតិមាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

ឧបសម្ព័ន្ធ ១-ក

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំចូលជាសមាជិកសភាផាត់ទាត់

ឈ្មោះអ្នកសុំ: ..........................................................................................................

ឋានៈ : ..........................................................................................................

អាសយដ្ឋាន : ..........................................................................................................

អាសយដ្ឋានប្រៃសណីយ៍ : ..........................................................................................

ទូរស័ព្ទ : ..........................................................................................................

**ជូនចំពោះ លោកប្រធានសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល**

ក្រោយពីបានស្វែងយល់ ប្រកាសស្តីពី សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល លេខ....... ចុះថ្ងៃទី.......ខែ.........ឆ្នាំ........និងដើម្បីសំរួលដល់ការប្រើប្រាស់មូលប្បទានប័ត្ររវាងធនាគារយើងខ្ញុំ និងធនាគារដទៃទៀតក្នុងទីក្រុងភ្នំពេញ

យើងខ្ញុំសុំស្នើលោកប្រធានសភាផាត់ទាត់ មេត្តាពិនិត្យនិងសំរេចអោយធនាគារយើងខ្ញុំបានចូលជាសមាជិកនៃសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ដោយអនុគ្រោះ ។

សូមជូនភ្ជាប់ជាមួយនូវ ÷

- ច្បាប់ចតចម្លងនៃអាជ្ញាប័ណ្ណធ្វើអាជីវកម្មធនាគារ ១ច្បាប់
- លិខិតឧទ្ទេសនាម និងគំរូហត្ថលេខា ៣ច្បាប់

យើងខ្ញុំសន្យាថា នឹងគោរព អនុវត្តនូវខ្លឹមសារប្រកាសខាងលើដោយម៉ឺងម៉ាត់ ។

សូមលោកប្រធានទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ

ភ្នំពេញ, ថ្ងៃទី ...........ខែ ........... ឆ្នាំ ២០០

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**

**<u>ឧបសម្ព័ន្ធ</u> ១-ខ** ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារ** ...........................................

សូមឧទ្ទេសនាមនូវឈ្មោះ និងគំរូហត្ថលេខារបស់លោក-លោកស្រី ក្នុងធនាគារយើងខ្ញុំដែលមានសិទ្ធិចុះហត្ថលេខាជាផ្លូវការលើលិខិតយុត្តិការ និងសំបុត្រស្នាមផាត់ទាត់របស់ធនាគារយើងខ្ញុំនៅធនាគារជាតិនៃកម្ពុជា ដើម្បីបំរើការងារសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ។

ក/-<u>គណ:កម្មាធិការសភាផាត់ទាត់</u> :

| | | |
|---|---|---|
| នាយកធនាគារ<br>ឈ្មោះ ..................................... | | |
| តំណាងទទួលសិទ្ធិ<br>ឋាន: ......................................<br>ឈ្មោះ ...................................... | | |

ខ/-<u>តំណាងចូលរួមគ្រាផាត់ទាត់</u> (វត្តមានចាំបាច់ ១រូប)

| | | |
|---|---|---|
| តំណាង<br>ឋាន: ....................................<br>ឈ្មោះ .................................. | | |
| តំណាងទទួលសិទ្ធិ<br>ឋាន: ....................................<br>ឈ្មោះ .................................. | | |

ពេលដែលលោក-លោកស្រីខាងលើមានការផ្លាស់ប្តូរភារកិច្ច យើងខ្ញុំនឹងឧទ្ទេសនាមឈ្មោះ និងគំរូហត្ថលេខាជាថ្មីឡើងវិញ ។

គំរូហត្ថលេខានេះមានប្រសិទ្ធិភាពប្រើប្រាស់ចាប់

ពីថ្ងៃទី ...................ដល់ ...........................

ភ្នំពេញ,ថ្ងៃទី ......ខែ ....... ឆ្នាំ ២០០

ប្រធានសភាផាត់ទាត់

ភ្នំពេញ, ថ្ងៃទី ..........ខែ ......... ឆ្នាំ ២០០

ហត្ថលេខា

**<u>ឧបសម្ព័ន្ធ</u> ២**

# បញ្ជីរាយនាមសមាជិក

## សភាផាត់ទាត់មូលប្បទានបត្រចរឹកជាប្រាក់រៀល

| លេខរៀង | ឈ្មោះធនាគារ | អក្សរសំគាល់ | លេខអត្តសញ្ញាណ |
|---|---|---|---|
| ១ | ធនាគារជាតិនៃកម្ពុជា | NBC | |
| ២ | រតនាគារជាតិ | NTG | T001 |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | FTB | B001 |
| ៤ | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | CCB | B003 |
| ៥ | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | CPB | B004 |
| ៦ | ធនាគារ កាណាឌីយ៉ា | CNB | B005 |
| ៧ | ធនាគារ ក្រុងថៃ | KTB | B009 |
| ៨ | ធនាគារ កសិករថៃ | TFB | B012 |
| ៩ | ធនាគារ ក្រេឌីតអាគ្រីកូលឥណ្ឌូស៊ុយអេស៍ | CAI | B013 |
| ១០ | ធនាគារ កម្ពុជាអាស៊ី | CAB | B016 |
| ១១ | សាជីវកម្មធនាគារសឹង្ហបូរី | SBC | B018 |
| ១២ | ធនាគារ មេយប៉ែង | MBB | B020 |
| ១៣ | ធនាគារ សឹង្ហបូរីពាណិជ្ជ | SCB | B021 |
| ១៤ | ធនាគារ ស្តាន់ដារឆាទើរ៉ែត | $SCB_1$ | B025 |
| ១៥ | ធនាគារ សហពាណិជ្ជ | UCB | B026 |
| ១៦ | ធនាគារ ក្រៅប្រទេសទី១ | FOB | B031 |

**<u>ឧបសម្ព័ន្ធ ៣</u>**

## មូលហេតុដែលបានព្រមព្រៀងសំរាប់ការបង្វិលវិញនូវមូលប្បទានប័ត្រ

១- សំវិធានវត្ថុគ្មាន ឬមិនគ្រប់គ្រាន់
២- សំវិធានវត្ថុមិនទាន់បានជំរះ
៣- បញ្ឈប់ការទូទាត់
៤- បុរេបរិច្ឆេទ និង កាលបរិច្ឆេទមិនត្រឹមត្រូវ
៥- ហួសកាលបរិច្ឆេទ( លើសពី ៦ខែ )
៦- ចំនួនទឹកប្រាក់ជាអក្សរ និង ជាលេខខុសគ្នា
៧- ខ្វះចំនួនទឹកប្រាក់ជាអក្សរ
៨- ហត្ថលេខារបស់បហារ៉ិកខុសពីគំរូហត្ថលេខា
៩- ខ្វះហត្ថលេខារបស់បហារ៉ិក
១០- ខ្វះហត្ថលេខារបស់បហារ៉ិកចំពោះការផ្លាស់ប្តូរ
១១- មិនចេញផ្សាយតាមគំរូធនាគារ
១២- មូលប្បទានប័ត្រខ្មៅខ្មី
១៣- គណនីត្រូវបានបិទ
១៤- គ្មានគណនី
១៥- បហារ៉ិកទទួលមរណភាព
១៦- បហារ៉ិកធនក្ស័យ ត្រូវជំរះបញ្ជី

**ឧបសម្ព័ន្ធ ៤**

**គំរូ PPC001 : កត់ត្រាមូលប្បទានប័ត្ររបស់ធនាគារនីមួយៗប្រគល់ឱ្យសភាផាត់ទាត់**

## សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

មូលប្បទានប័ត្រប្រគល់ដោយធនាគារ .......................................... ចំពោះធនាគារ ..........................................

ថ្ងៃទី ...........................................

| | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
|---|---|---|---|---|---|
| 1 | | | 35 | | |
| 2 | | | 36 | | |
| 3 | | | 37 | | |
| 4 | | | 38 | | |
| 5 | | | 39 | | |
| 6 | | | 40 | | |
| 7 | | | 41 | | |
| 8 | | | 42 | | |
| 9 | | | 43 | | |
| 10 | | | 44 | | |
| 11 | | | 45 | | |
| 12 | | | 46 | | |
| 13 | | | 47 | | |
| 14 | | | 48 | | |
| 15 | | | 49 | | |
| 16 | | | 50 | | |
| 17 | | | 51 | | |
| 18 | | | 52 | | |
| 19 | | | 53 | | |
| 20 | | | 54 | | |
| 21 | | | បូកសរុបមូលប្បទានប័ត្រថ្មី | | |
| 22 | | | | | |
| 23 | | | មូលប្បទានប័ត្របង្វិលវិញ | | |
| 24 | | | | | |
| 25 | | | | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
| 26 | | | | | |
| 27 | | | 1 | | |
| 28 | | | 2 | | |
| 29 | | | 3 | | |
| 30 | | | 4 | | |
| 31 | | | 5 | | |
| 32 | | | 6 | | |
| 33 | | | 7 | | |
| 34 | | | 8 | | |
| | សរុប : | | សរុបមូលប្បទានប័ត្របង្វិលវិញ | | |
| | | សរុបមូលប្បទានប័ត្រថ្មីនិងមូលប្បទានប័ត្របង្វិលវិញ | | | |

សំរាប់ប្រើប្រាស់ក្នុងសភាផាត់ទាត់

ហត្ថលេខា .........................

# សេចក្តីជូនដំណឹងអំពីប័ណ្ណទានរបស់ប្រតិបត្តិការប្រាក់រៀល

## សំរង់មូលប្បទានប័ត្រចារឹកជារៀលមិនអាចទូទាត់បាន

មូលប្បទានប័ត្រនៃគ្រាផាត់ទាត់ ថ្ងៃទី ...................................

ពីធនាគារ ........................................................................

ចំពោះធនាគារ ..................................................................

សំរាប់គ្រាផាត់ទាត់ថ្ងៃទី .....................................................

| លេខរៀង | មូលប្បទានប័ត្រលេខ | ចំនួនទឹកប្រាក់ជារៀល |
|---|---|---|
| | | |
| **សរុប :** | | |

មូលប្បទានប័ត្រទាំងនេះនឹងត្រូវបានរាយរាប់ក្នុងគំរូ PPC001 នៃគ្រាផាត់ទាត់ថ្ងៃទី ...........................
សំរាប់មូលប្បទានប័ត្រមិនអាចទូទាត់ ត្រូវបង្វិលវិញ ។

ហត្ថលេខា"ធនាគារប្រគល់" .............................

ហត្ថលេខា"ធនាគារទទួល" ..............................

គំរូPPC002 : **កត់ត្រាសង្ខេបតាមធនាគារនូវមូលប្បទានប័ត្របានប្រគល់ឱ្យសភាផាត់ទាត់**

## សភាផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល

មូលប្បទានប័ត្រប្រគល់ដោយ .................................... "ឈ្មោះធនាគារ" ឥណពន្ធគណនី : .............

នៅ ................. "ម៉ោង" នាគ្រាផាត់ទាត់ ..................... "កាលបរិច្ឆេទ" ឥណទានគណនី : .............

| ល.រ | លេខសំគាល់ ធនាគារ | ធនាគារ | មូលប្បទានប័ត្រប្រគល់ "សំវិធានវត្ថុត្រូវទទួល" | ចំនួន | មូលប្បទានប័ត្រទទួល "សំវិធានវត្ថុត្រូវសងធនាគារដទៃ" | ចំនួន | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ត្រូវទទួល | ត្រូវសង |
| 1 | | | | | | | | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |
| 5 | | | | | | | | |
| 6 | | | | | | | | |
| 7 | | | | | | | | |
| 8 | | | | | | | | |
| 9 | | | | | | | | |
| 10 | | | | | | | | |
| 11 | | | | | | | | |
| 12 | | | | | | | | |
| 13 | | | | | | | | |
| 14 | | | | | | | | |
| 15 | | | | | | | | |
| 16 | | | | | | | | |
| | សរុប : | | | | | | | |

ហត្ថលេខា ............................... "ធនាគារប្រគល់ឬទទួល"

ហត្ថលេខា ............................... "ធនាគារជាតិនៃកម្ពុជា"

គំរូ**PPC003 : កត់ត្រានូវលទ្ធផលផាត់ទាត់សរុបតាមធនាគារនីមួយៗ**

## សតាផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល

នៅ ................ "ម៉ោង" នាគ្រាផាត់ទាត់ .................... "កាលបរិច្ឆេទ"

| ល.រ | លេខសំគាល់ ធនាគារ | ធនាគារ | "សិរិធានវត្ថុត្រូវសងធនាគារដទៃ" | ចំនួន | "សិរិធានវត្ថុត្រូវទទួលពីធនាគារដទៃ" | ចំនួន | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ត្រូវទទួល | ត្រូវសង |
| 1 | | | | | | | | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |
| 5 | | | | | | | | |
| 6 | | | | | | | | |
| 7 | | | | | | | | |
| 8 | | | | | | | | |
| 9 | | | | | | | | |
| 10 | | | | | | | | |
| 11 | | | | | | | | |
| 12 | | | | | | | | |
| 13 | | | | | | | | |
| 14 | | | | | | | | |
| 15 | | | | | | | | |
| 16 | | | | | | | | |
| | សរុប : | | | | | | | |

ហត្ថលេខា .............................. "ធនាគារជាតិនៃកម្ពុជា"